ភ្នំពេញ , ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៩៣

**សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការបង្កើតគណៈកម្មការ**
**វាយតំលៃអំណោយរបស់ក្រុម អ៊ិនតាក់ ជប៉ុន**
**ប្រចាំការនៅខេត្តតាកែវ**

****

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះមុខរដ្ឋនៃកម្ពុជា ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃ កម្ពុជា
- យោងសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការវាយតំលៃអំណោយរបស់ក្រុម អ៊ិនតាក់ ជប៉ុនប្រចាំនៅខេត្តតាកែវរួម មានសមាសភាពដូច តទៅ ÷

- តំណាង ក្រសួងហិរញ្ញវត្ថុ ជាប្រធាន
- តំណាងក្រសួង ផែនការ ជាអនុប្រធាន
- តំណាង ក្រសួងថាមពល និង រ៉ែ ជាសមាជិក
- តំណាង ក្រសួងកិច្ចការនារី យុវជន និង កីឡា ជាសមាជិក
- លោក ឌី សុភីន តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
- តំណាង រដ្ឋករទឹក រដ្ឋធានីភ្នំពេញ ជាសមាជិក
- តំណាង ខេត្តតាកែវ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ចុះពិនិត្យ និង វាយតំលៃអំណោយទាំងអស់ដែលក្រុម អ៊ិនតាក់ ជប៉ុន ប្រចាំខេត្តតាកែវ បានផ្តល់ជូនរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា ។ ធ្វើបញ្ជីសារពើភណ្ឌ តាមយថាប្រភេទ និង បរិមាណអោយបានច្បាស់លាស់ ហើយរាយការណ៍ជូនរដ្ឋាភិបាល ជាតិបណ្តោះនៃកម្ពុជា។

**ប្រការ ៣ :** គណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងចុះបំពេញបេសកកម្ម

នៅក្នុងសប្តាហ៍ទី ១ នៃ ខែ សីហា ឆ្នាំ ១៩៩៣ នេះ ។

**ប្រការ ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានរដ្ឋាករទឹក និង អភិបាលខេត្តតាកែវ ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

## ជ. រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

**សហប្រធានរដ្ឋមន្ត្រី**

ហត្ថលេខា ហត្ថលេខា

**ញាត ឈន់ អ៊ុខ ផន**

ភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៣

**លេខ ៣៤០១ អស កបជ**

រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
សូមគោរពថ្វាយស្តេចក្រុមហ្លួង និង ជូនឯកឧត្តមសហប្រធាន
ក្រុមប្រឹក្សារដ្ឋមន្ត្រី

**កម្មវត្ថុ :** បញ្ហាស្នើសុំទ្វារៈបរិក្ខារបស់អង្គភាពទ័ពជប៉ុនក្នុងអ៊ុនតាក់

**យោង :** លិខិតចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ផ្ញើជូននាយករដ្ឋមន្ត្រីជប៉ុន

ទូលបង្គំ ខ្ញុំមានកិត្តិយសសូមទូលថ្វាយព្រះអង្គស្តេចក្រុមហ្លួង និង ឯកឧត្តមសហប្រធានជា